# មហាអនុតំបន់មេគង្គដែលគ្មានភាពក្រីក្រ និង មានប្រព័ន្ធអេកូឡូស៊ីសម្បូរបែប



ADB

កម្មវិធីបរិស្ថានស្នូល និង កិច្ចផ្តួចផ្តើមច្រករបៀងការអភិរក្សជីវៈចម្រុះ



# សម្បូរបែប...

មហាអនុតំបន់មេគង្គ (GMS) លាតសន្ធឹងលើផ្ទៃដីធំជាង ២,៥លានគីឡូម៉ែត្រការ៉េ ជាទីតាំងមួយសម្បូរដោយប្រព័ន្ធអេកូឡូស៊ីមានតម្លៃនិងផលិតភាពខ្ពស់បំផុត ប៉ុន្តែងាយរងគ្រោះ។ អាកាសធាតុ ភ្នំ ព្រៃឈើ ដីនិងទន្លេ មាន លក្ខណៈអំណោយផលទ្រទ្រង់ដល់រុក្ខជាតិ និងសត្វជាច្រើនបែប រួមមានប្រភេទសត្វជានិមិត្តរូប ដូចជាខ្លាដំបង និងដំរីអាស៊ី។

មហាអនុតំបន់មេគង្គដែលផ្តល់ជាជម្រកសម្រាប់ប្រជាជន ៣៣២លាននាក់ និងជនជាតិដើមចំនួនច្រើនជាង ៧០ក្រុម គឺជាកន្លែងដែលមានបេតិកភណ្ឌវប្បធម៌ និងភាសាដ៏សម្បូរបែប។ ប្រជាជនច្រើនជាងពីរភាគបីនៅក្នុងអនុតំបន់នេះប្រកបរបរកសិកម្ម និងពឹងផ្អែកលើធម្មជាតិដ៏សម្បូរបែបនេះ ជាប្រភពប្រាក់ចំណូល និងសម្រាប់ការរស់នៅប្រចាំថ្ងៃ។

អាស្រ័យដោយភាពស្មុគស្មាញនៃធនធានធម្មជាតិដ៏មានតម្លៃ ដែនដីនៃមហាអនុតំបន់មេគង្គផ្តល់ឈើ រ៉ែ ត្បូងថ្ម និងប្រេងកាត រួមទាំងទឹកទន្លេដូចជា ទន្លេមេគង្គ ទ្រទ្រង់ដល់កសិកម្ម ជលផល និងថាមពលវារីអគ្គិសនី។



## ...ប៉ុន្តែងាយរងគ្រោះ

ក្នុងនាមជាតំបន់មួយលើពិភពលោកដែលមានការលូតលាស់ឆាប់រហ័សបំផុត ការអភិវឌ្ឍសេដ្ឋកិច្ចឆាប់រហ័សបាននាំមកនូវវិបុលភាពដល់ប្រជាជនយ៉ាងច្រើននៅក្នុងមហាអនុតំបន់នេះ ហើយប្រទេសទាំងប្រាំមួយនៃមហាអនុតំបន់នេះស្ថិតក្នុងគន្លងដែលអាចឈានដល់ការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍សំខាន់ៗ។

ទោះជាយ៉ាងណាក៏ដោយ កំណើនសេដ្ឋកិច្ចបានកើតឡើងទន្ទឹមនឹងការខូចខាតយ៉ាងច្រើនទៅលើបរិស្ថាន។ ព្រៃដើមភាគច្រើន និងជីវៈចម្រុះដ៏មានតម្លៃនៅក្នុងអនុតំបន់នេះ បានរងការបំផ្លិចបំផ្លាញ ឬខូចខាត។ការបំពុលខ្យល់ និងទឹក ឱនភាពដីធ្លី និងការដាច់ដោចនៃប្រព័ន្ធអេកូឡូស៊ី ត្រូវបានកត់ត្រាទុកនិងបង្ហាញអោយឃើញយ៉ាងច្បាស់។

ជាមួយកំណើនតម្រូវការធនធានធម្មជាតិយ៉ាងច្រើនពុំធ្លាប់មានពីមុនមក និងកង្វល់កាន់តែខ្លាំងឡើងអំពីការប្រែប្រួលអាកាសធាតុ និងទឹកថាមពល រួមទាំងសន្តិសុខស្បៀង ការអភិវឌ្ឍតាមទម្លាប់ពីមុនមិនអាចសម្រេចជោគជ័យឡើយ ដូច្នេះទាមទារឲ្យមានវិធានមួយដែលមាននិរន្តរភាពជាងមុន។ សេដ្ឋកិច្ចបៃតងដែលមានមូលដ្ឋានគ្រឹះចេញពីប្រសិទ្ធភាព និងសមធម៌ ដែលក្នុងនោះមានការឲ្យតម្លៃខ្ពស់និងការកែលម្អគុណភាពប្រសើរជាងមុនចំពោះសម្បត្តិធម្មជាតិ  គឺជាវិធីតែមួយគត់ក្នុងការឈានទៅធ្វើឲ្យមហាអនុតំបន់មេគង្គគ្មានភាពក្រីក្រ និងមានប្រព័ន្ធអេកូឡូស៊ីសម្បូរបែប។



## កម្មវិធីបរិស្ថានស្នូល

កម្មវិធីបរិស្ថានស្នូល និងកិច្ចផ្តួចផ្តើមច្រករបៀងការអភិរក្សជីវៈចម្រុះ (CEP-BCI) កំពុងជួយបណ្តាប្រទេសក្នុងមហាអនុតំបន់មេគង្គដោះស្រាយបញ្ហាបរិស្ថានសំខាន់ៗ និងសម្រេចបានការអភិវឌ្ឍដោយចីរភាព។

ដឹកនាំដោយរដ្ឋាភិបាលក្នុងមហាអនុតំបន់មេគង្គ ជាមួយការសង្កត់ធ្ងន់លើការកសាងសមត្ថភាព កម្មវិធីនេះផ្តល់ជាវេទិកាមួយសម្រាប់កិច្ចសហការរវាងប្រទេសជាច្រើន និងពហុវិស័យ ដើម្បីសុខុដុម្មនីយកម្មកំណើនសេដ្ឋកិច្ចជាមួយការគ្រប់គ្រងបរិស្ថានល្អ។

## កម្មវិធី CEP-BCI: ដំណើររឿងមកទល់ពេលនេះ...

នៅឆ្នាំ ១៩៩២ តាមរយៈជំនួយគាំទ្រពីធនាគារអភិវឌ្ឍន៍អាស៊ី (ADB) និងផ្អែកលើប្រវត្តិសាស្ត្រ និងវប្បធម៌រួមគ្នា ប្រទេសទាំងប្រាំមួយក្នុងមហាអនុតំបន់មេគង្គបានប្រកាសចាប់ផ្តើមកម្មវិធីសហប្រតិបត្តិការសេដ្ឋកិច្ចអនុតំបន់ ពោលគឺ កម្មវិធីមហាអនុតំបន់មេគង្គ ដើម្បីពង្រឹងទំនាក់ទំនងសេដ្ឋកិច្ចរបស់ខ្លួន។ កម្មវិធីនេះ បានជួយបង្កើនវិបុលភាពនៅក្នុងអនុតំបន់នេះ តាមរយៈការវិនិយោគទឹកប្រាក់ច្រើនជាង១៥ពាន់លានដុល្លាអាមេរិកលើផ្លូវថ្នល់ ព្រលានយន្តហោះ ផ្លូវដែក ថាមពលវារីអគ្គីសនីហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍ និងការអភិវឌ្ឍទីក្រុង។

ជាការឆ្លើយតបទៅនឹងកំណើននៃការព្រួយបារម្ភអំពីផលប៉ះពាល់បរិស្ថានពីការអភិវឌ្ឍសេដ្ឋកិច្ចយ៉ាងឆាប់រហ័ស នៅឆ្នាំ២០០៥ ប្រទេសក្នុងមហាអនុតំបន់មេគង្គបានបង្កើតកម្មវិធី CEP-BCI។ នៅក្រោមការចាត់ចែងរបស់ ADB និងមានក្រសួងបរិស្ថាននៃប្រទេសទាំងប្រាំមួយជាអ្នកមើលការខុសត្រូវ កម្មវិធី CEP-BCI មានគោលដៅសម្រេចឲ្យបាននូវ″កម្មវិធីមហាអនុតំបន់មេគង្គមួយដែលមានមេត្រីភាពជាមួយបរិស្ថាន និងដែលធន់ទ្រាំអាកាសធាតុ″។ កម្មវិធីនេះស្ថិតក្រោមការសម្របសម្រួលដោយមជ្ឈមណ្ឌលប្រតិបត្តិការបរិស្ថាន ដែលនៅចំណុះបេសកកម្មរបស់ ADB ប្រចាំនៅប្រទេសថៃ។

នៅក្នុងដំណាក់កាលសាកល្បងឆ្នាំ ២០០៦-២០១១ កម្មវិធី CEP-BCI បានកែលម្អការគ្រប់គ្រងបរិស្ថាននៅក្នុងមហាអនុតំបន់មេគង្គ ដោយពង្រឹងដំណើរការកសាងផែនការ គាំទ្រដល់ការលើកកំពស់ជីវៈចម្រុះ និងការប្រកបរបរចិញ្ចឹមជីវិតនៅក្នុងតំបន់អភិរក្សសំខាន់ៗ រួមទាំងកែលម្អប្រព័ន្ធពិនិត្យតាមដានថ្នាក់ជាតិនានា ។ ដោយមានការទទួលស្គាល់អំពីសមិទ្ធផល និងការបន្តមានភាពចាំបាច់នៃកម្មវិធីនេះ នៅឆ្នាំ ២០១១ កម្មវិធីនេះត្រូវបានអនុម័តអោយមានដំណាក់កាលថ្មីមួយដែលមានរយៈពេលប្រាំឆ្នាំ ដោយការអនុវត្តបានចាប់ផ្តើមនៅពាក់កណ្តាលឆ្នាំ ២០១២។

# តើត្រូវធ្វើអ្វីខ្លះ

កម្មវិធី CEP-BCI ណែនាំឲ្យប្រើប្រាស់ឧបករណ៍ និងដំណើរការនានាខាងបរិស្ថាន កសាងសមត្ថភាព និងពង្រឹងការប្រើប្រាស់ឧបករណ៍ និងដំណើរការទាំងនេះ នៅក្នុងការអភិវឌ្ឍសេដ្ឋកិច្ច។ កម្មវិធីនេះបានផ្តោតលើការវាយតម្លៃបរិស្ថាន ការកសាងផែនការ ការសាកល្បងអនុវត្តការច្នៃប្រឌិតថ្មីៗ និងការពិនិត្យតាមដាន ទាំងនេះរួមគ្នាគឺជាធាតុផ្សំដ៏សំខាន់សម្រាប់ការគ្រប់គ្រងបរិស្ថានឲ្យបានល្អ។

## ការប៉ាន់ប្រមាណអំពីការប្រឈម និងកាលានុវត្តភាពក្នុងវិស័យបរិស្ថាន

ការអភិវឌ្ឍដែលមានមេត្រីភាពជាមួយបរិស្ថាន មានន័យថា ការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយប្រសិទ្ធភាព សមធម៌ និងនិរន្តរភាព។ វាមានភាពចាំបាច់ណាស់ដែលត្រូវដឹងថាតើមានធនធានអ្វីខ្លះនៅទីនោះ គុណតម្លៃធៀបនៃធនធានទាំងនោះ និងថាតើមានអ្វីកើតឡើងចំពោះធនធានទាំងនោះ។ ជាមួយព័ត៌មាននេះ អ្នកកសាងផែនការអភិវឌ្ឍន៍អាចធ្វើការសម្រេចចិត្តដោយផ្អែកលើការយល់ដឹងនិងបានល្អជាងមុន ។

កម្មវិធី CEP-BCI កំពុងកសាងសមត្ថភាពនៅក្នុងមហាអនុតំបន់មេគង្គ ឲ្យយល់ដឹងអំពីសម្ពាធនានាលើធនធានធម្មជាតិ ដែល រួមទាំងការយល់អំពីគុណតម្លៃនៃសេវាប្រព័ន្ធអេកូឡូស៊ី ដូចជា ការផ្តល់ទឹកនិងដី និយ័តកម្មអាកាសធាតុ ការវិភាគអំពីការគំរាមកំហែងដែលបង្កដោយបញ្ហានានា ដូចជាការប្រែប្រួលអាកាសធាតុ និងកំណត់អត្តសញ្ញាណឱកាសសម្រាប់ការចិញ្ចឹមជីវិតប្រកបដោយនិរន្តរភាព។

## ជម្រុញការកសាងផែនការដែលមាននិរន្តរភាពបរិស្ថាន

ការអភិវឌ្ឍក្នុងមហាអនុតំបន់មេគង្គ ស្ថិតក្រោមឥទ្ធិពលនៃផែនការគ្រប់លំដាប់ថ្នាក់ដូចជា យុទ្ធសាស្ត្រទេសចរណ៍កម្រិតអនុតំបន់ ផែនការសេដ្ឋកិច្ចសង្គមនៅថ្នាក់ជាតិ និងតាមវិស័យ ក៏ដូចជា ផែនការប្រើប្រាស់ដីនៅថ្នាក់ខេត្តផងដែរ។

កម្មវិធី CEP-BCI ចូលរួមនៅក្នុងដំណើរការកសាងផែនការនៃវិស័យជាអាទិភាពនៅក្នុងកម្មវិធីមហាអនុតំបន់មេគង្គ ដែលរួមទាំង ការដឹកជញ្ជូន កសិកម្ម ថាមពល ទេសចរណ៍ ដើម្បីធានាឲ្យមានការពិចារណាអំពីបរិស្ថាន។ នៅក្នុងនេះ ការវាយតម្លៃបរិស្ថានកំពុងត្រូវបានបញ្ជ្រាបទៅក្នុងផែនការតាមវិស័យ និងគម្រោងអភិវឌ្ឍន៍នៅក្នុងមហាអនុតំបន់មេគង្គ។

### ព័ត៌មានសង្ខេប – កម្មវិធី CEP-BCI ដំណាក់កាលទី ២

**រយៈពេល៖** ឆ្នាំ ២០១២–២០១៦

**ទឹកប្រាក់វិនិយោគ៖** ២៨,៤លានដុល្លាអាមេរិក

**ស្ថាប័នផ្តល់ហិរញ្ញវត្ថុ៖** ADB, រដ្ឋាភិបាលហ្វាំងឡង់,ទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិស៊ុយអែដ, មូលនិធិអភិវឌ្ឍន៍របស់ប្រទេសអឺរ៉ុបខាងជើង

**ត្រួតពិនិត្យដោយ៖** ក្រុមការងារបរិស្ថាននៃមហាអនុតំបន់មេគង្គ

- ព្រះរាជាណាចក្រកម្ពុជា – ក្រសួងបរិស្ថាន
- សាធារណរដ្ឋប្រជាមានិតចិន – ក្រសួងការពាបរិស្ថាន
- សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ – ក្រសួងធនធានធម្មជាតិ និងបរិស្ថាន
- សាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា – ក្រសួងអភិរក្សបរិស្ថាន និងព្រៃឈើ
- ព្រះរាជាណាចក្រថៃ – ក្រសួងធនធានធម្មជាតិ និងបរិស្ថាន
- សាធារណរដ្ឋសង្គមនិយមវៀតណាម – ក្រសួងធនធានធម្មជាតិ និងបរិស្ថាន

**ស្ថាប័នចាត់ចែងរដ្ឋបាល៖** ADB – ជំនួយបច្ចេកទេសថ្នាក់តំបន់ (RETA) ៧៩៨៧

**លេខាធិការដ្ឋាន៖** មជ្ឈមណ្ឌលប្រតិបត្តិការបរិស្ថាននៃ GMS




## ការសាកល្បងលើការច្នៃប្រឌិតថ្មីៗ

យុទ្ធសាស្ត្រធម្មតាជាច្រើនសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចគឺគ្មាននិរន្តរភាពឡើយ។ កម្មវិធី CEP-BCI ត្រូវបានបង្កើតឡើង ដើម្បីសាកល្បងអនុវត្តវិធីច្នៃប្រឌិតនិងដាក់ស្តែងដើម្បីទទួលផលប្រសើរជាងមុន លើផ្នែកបរិស្ថាន និងសង្គម។

មកទល់ពេលនេះ ការងារសាកល្បងបានផ្តោតលើការទប់ស្កាត់ភាពដាច់ដោចនៃប្រព័ន្ធអេកូឡូស៊ី តាមរយៈការអភិរក្សជីវៈចម្រុះនៃ"ច្រករបៀង" ដែលតភ្ជាប់តំបន់ការពារធម្មជាតិនានា។ កម្មវិធីសាកល្បងទាំងនេះចាត់ទុកសហគមន៍មូលដ្ឋានគឺជាស្នូលនៃកិច្ចប្រឹងប្រែងអភិរក្ស និងជួយពង្រឹងរបរចិញ្ចឹមជីវិតនៅមូលដ្ឋាន ដោយបង្កើតចំណងទាក់ទងជាមួយឱកាសសេដ្ឋកិច្ច"បៃតង"។ កិច្ចផ្តួចផ្តើមសាកល្បងដទៃទៀត រួមមាន ការដឹកជញ្ជូនទំនិញដោយបញ្ចេញកាបូនកម្រិតទាប ការបន្សាំ និងការកាត់បន្ថយការប្រែប្រួលអាកាសធាតុនៅថ្នាក់មូលដ្ឋាន។

## ការពិនិត្យតាមដានដំណើរការបរិស្ថាន

ការពិនិត្យដំណើរការបរិស្ថានមានសារៈសំខាន់ សម្រាប់ការស្វែងយល់អំពីផលប៉ះពាល់នៃការអភិវឌ្ឍ និងជាមូលដ្ឋានគ្រឹះសម្រាប់ដំណើរការកសាងផែនការ។ កម្មវិធី CEP-BCI គាំទ្រដល់រដ្ឋាភិបាលក្នុងមហាអនុតំបន់មេគង្គ ដើម្បីពិនិត្យតាមដាននិន្នាការបរិស្ថានជាទូទៅ និងវឌ្ឍនភាពឆ្ពោះទៅសម្រេចគោលដៅអភិវឌ្ឍជាតិ ក៏ដូចជាលទ្ធផលនៃការធ្វើអន្តរាគមន៍នានាលើការអភិវឌ្ឍផងដែរ។

កម្មវិធី CEP-BCI គាំទ្រកិច្ចការនេះតាមរយៈការវាយតម្លៃដំណើរការខាងបរិស្ថាននៅថ្នាក់ជាតិ និងតាមរយៈការបង្កើតវេទិកា ដើម្បីធានាឲ្យមានទិន្នន័យបរិស្ថានថ្មីៗ ដល់អ្នកកសាងផែនការអភិវឌ្ឍន៍ និងអ្នកពាក់ព័ន្ធដទៃទៀត។









## លទ្ធផល

កម្មវិធី CEP-BCI បានធ្វើឲ្យមានឥទ្ធិពល រយៈពេលវែងលើការពង្រឹងការគ្រប់គ្រងបរិស្ថាននៅក្នុងមហាអនុតំបន់មេគង្គ។ ការគូសបញ្ជាក់ខ្លះៗ មានជាអាទិ៍៖

- ទំនុកចិត្ត និងកិច្ចសហការរវាងក្រសួងបរិស្ថាននៅក្នុងមហាអនុតំបន់មេគង្គ ត្រូវបានបង្កើតឡើងយ៉ាងរឹងមាំ ហើយកិច្ចសហប្រតិបត្តិការជាមួយវិស័យសេដ្ឋកិច្ចសំខាន់ៗត្រូវបានកែលម្អ។
- សមត្ថភាពកសាងផែនការក្នុងមហាអនុតំបន់មេគង្គត្រូវបានពង្រឹង ដោយការអនុវត្តនូវការវាយតម្លៃបរិស្ថានបែបយុទ្ធសាស្ត្រចំនួនប្រាំមួយ ដែលនាំឲ្យមានភាពប្រសើរឡើងនៃការអភិវឌ្ឍថាមពល ទេសចរណ៍ និងផែនការប្រើប្រាស់ដីធ្លីនៅថ្នាក់ជាតិ។
- ទីតាំងសាកល្បងច្រករបៀងការអភិរក្សជីវៈចម្រុះចំនួនប្រាំពីរត្រូវបានបង្កើត ដោយបច្ចុប្បន្នផ្ទៃដីធំជាងមួយលានហិកតា ស្ថិតនៅក្រោមការគ្រប់គ្រងដោយនិរន្តរភាព និងប្រជាជនច្រើនជាង ២៨.០០០ គ្រួសារទទួលផលពីកិច្ចផ្តួចផ្តើមផ្តោតលើការចិញ្ចឹមជីវិត។ ជោគជ័យនៃការសាកល្បងនេះមានឥទ្ធិពលដោយផ្ទាល់មកលើការបង្កើនប្រាក់កម្ចីពី ADB ចំនួន ៦៩ លានដុល្លាអាមេរិក ដល់កម្ពុជា ឡាវ និងវៀតណាម សម្រាប់ពង្រីកការអភិរក្សជីវៈចម្រុះតាមរយៈការងារច្រករបៀង។
- ប្រព័ន្ធ និងសមត្ថភាពនៅក្នុងប្រទេសលើការពិនិត្យតាមដាននិន្នាការ និងដំណើរការបរិស្ថាន ត្រូវបានពង្រឹង។

# THE GREATER MEKONG SUBREGION




ADB

GMS Environment Operations Center
23rd Floor The Offices at Central World 999/9 Rama 1 Road, Pathumwan
Bangkok 10330 Thailand Tel: (+66) 2 207 4444 Fax: (+66) 2 207 4400 Email: info@gms-eoc.org
Website: www.gms-eoc.org

Photo credits: Steve Griffiths